ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ និង ឈ្មោះសំណុំរឿង ៖ ១០៤/១៩ - បូវយើរ ហ្គាមេន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ិន**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត**
អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៦៨៦ ៥១៥ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក ផុន សុវត្ថា ប្រធានផ្នែកធនធានមនុស្ស
២- លោក ទិត ពេជ្របញ្ញា ផ្នែកធនធានមនុស្ស

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត**
អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១៧ ៥១៥ ៥៩៥/០១២ ៣១០ ៨៩៦ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក សែម សំអឿន ប្រធានសហព័ន្ធសហជីពចលនាយុវជនដើម្បីសេរីភាព
២- លោក ចាន់ សុថា ប្រធានសហជីពមូលដ្ឋាន
៣- លោក ផង់ សិទ្ធី អនុប្រធានសហជីពមូលដ្ឋាន
៤- លោក ឈិត រស្មី លេខាសហជីពមូលដ្ឋាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org Website: www.arbitrationcouncil.org

៥- លោកស្រី ហង្ស ស្រីមុំ ប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្ពុជា

៦- លោកស្រី ហ៊ាន ស្រឿន អនុប្រធានសហជីពមូលដ្ឋាន

៧- លោកស្រី លី ផល្លា លេខាសហជីពមូលដ្ឋាន

៨- លោក សៀ សន ប្រធានសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

៩- លោកស្រី វ៉ង់ សុភ័ក ប្រធានសហជីពមូលដ្ឋាន

១០-លោក ចេត ចក់ អនុប្រធានសហជីពមូលដ្ឋាន

១១- លោកស្រី សយ ស្រីណែត លេខាសហជីពមូលដ្ឋាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនអនុវត្តការបើកប្រាក់ថ្លៃបាយបន្ថែមម៉ោងឱ្យបានទៀងទាត់ នៅរៀងរាល់ថ្ងៃសៅរ៍។

២- សុំឱ្យក្រុមហ៊ុនអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ ឬស្មើភាពគ្នាចំពោះកម្មករនិយោជិតដ៏ទៃទៀត និងឱ្យក្រុមហ៊ុនចាត់វិធានការបញ្ឈប់សកម្មភាព ចំពោះប្រតិភូបុគ្គលិក ឬតំណាងសហជីពជាពិសេសបុគ្គលឈ្មោះ ឆយ សុវណ្ណារី និង សេង សុភ័ណ្ឌ តែងតែដើរពេញក្រុមហ៊ុនដោយសេរី និងមិនបានធ្វើការពេញម៉ោងជូនក្រុមហ៊ុននោះទេ ហើយទទួលប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗពេញ ដដែល។

៣- សុំឱ្យក្រុមហ៊ុនបញ្ចូលភាគទានសហជីពអភិវឌ្ឍន៍កម្ពុជាទៅតាមគោលការណ៍ចាស់របស់ក្រុមហ៊ុន គឺចូលក្នុងប្រព័ន្ធគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា។

៤- សុំឱ្យក្រុមហ៊ុនអនុវត្តលិខិតរបស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល លេខ ៧៣០/១៩ ក.ប/កណ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ ដែលឱ្យក្រុមហ៊ុនត្រូវទទួលយកឈ្មោះ ហ៊ាន ស្រឿន ជាថ្នាក់ដឹកនាំសហជីពអភិវឌ្ឍន៍កម្ពុជាប្រចាំក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃក្រុមហ៊ុនបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។

៥- សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតដែលចូលរួមធ្វើកូដកម្មរយៈពេល ៧ថ្ងៃ នៅខែកក្កដា ឆ្នាំ២០១៩ កន្លងមក។

៦- សុំឱ្យក្រុមហ៊ុនបញ្ឈប់គណនេយ្យចេញពីការងារ ព្រោះបុគ្គលរូបនេះ បានឃុបឃិតជាមួយបុគ្គលម្នាក់ទៀតឈ្មោះ សេង សោភ័ណ្ឌ ដែលបានដកប្រាក់ភាគទានផ្ទាល់ដៃពីគណនី តាមគោលការណ៍ក្រុមហ៊ុន គឺតាមធនាគារ។

៧- សុំឱ្យក្រុមហ៊ុនដកក្រុមហ៊ុនសន្តិសុខវីអាយភី (VIP) ចេញពីក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ព្រោះក្រុមហ៊ុន VIP នេះ បានប្រើអំពើហិង្សាមកលើកម្មការិនី ហ៊ាន ស្រឿន នៅខាងមុខរោងចក្រ និងក្រុមហ៊ុន VIP នេះ ក៏បានជ្រៀតជ្រែកផ្ទៃក្នុង កិច្ចការផ្ទៃក្នុងសហជីព ថែមទៀតផង។

៨- សុំឱ្យក្រុមហ៊ុនអនុវត្តនូវសិទ្ធិសេរីភាពទៅលើថ្នាក់ដឹកនាំសហជីពដែលបានចុះបញ្ជីត្រឹមត្រូវ ឱ្យស្មើភាពគ្នា គឺមិនត្រូវរើសអើងនោះទេ។

THE ARBITRATION COUNCIL

៩- សុំឱ្យក្រុមហ៊ុនរៀបចំទឹកហូបជូនកម្មករនិយោជិតឱ្យបានគ្រប់គ្រាន់ និងប្រកបដោយមានអនាម័យ។

១០- សុំឱ្យក្រុមហ៊ុនចែក ឬផ្តល់ប្រាក់ភាគកម្មនៃប្រាក់ចំណេញ ជូនកម្មករនិយោជិតទាំងអស់។

១១- សុំឱ្យក្រុមហ៊ុនអនុវត្តការងារបន្ថែមម៉ោងផ្អែកលើគោលការណ៍ស្មគ្រចិត្ត ពីព្រោះក្រុមហ៊ុនបង្ខំឱ្យថែមម៉ោងជិតដល់ថ្ងៃ ឬចំថ្ងៃបើកប្រាក់ខែតែម្តង។

១២- សុំឱ្យក្រុមហ៊ុនជួយរើសកម្មករ(ប្រុស) ចំនួន ២នាក់ នៅផ្នែកតុកាត់ ដើម្បីជួយសម្រួលការងារធ្ងន់ៗ។

១៣- សុំឱ្យក្រុមហ៊ុនរៀបចំនៅអគារ B ឱ្យបានត្រឹមត្រូវ ព្រោះមានការលិចទឹកនៅពេលមេឃភ្លៀងម្តងៗ។

១៤- ចំពោះសហជីពមូលដ្ឋានដែលបានចុះបញ្ជីត្រឹមត្រូវ រួចបានដាក់ឈ្មោះសមាជិកដើម្បីកាត់ប្រាក់ភាគទាន សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលរបស់ពួកគាត់ ជូនសហជីព។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ៩៣៣/១៩ ក.ប/កណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ស្តីពីការស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារចំនួន ១៤ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជា

ជីវៈខេត្តកណ្ដាល បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារ និងផ្សះផ្សា នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជា ចំនួន ១៤ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) លេខ ៩៣៣/១៩ ក.ប/កណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១៤ចំណុច នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញា-កណ្ដាល។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមស្វែរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១៤ចំណុចនេះ និងផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាលើចំណុចវិវាទទី១, ទី២, ទី៦, ទី៨, ទី៩, ទី១១, ទី១២, ទី១៣, និងទី១៤។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាលើចំណុចវិវាទដែលនៅសល់ចំនួន ៥ចំណុច គឺចំណុចវិវាទទី៣, ទី៤, ទី៥, ទី៧, និងទី១០។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកំណត់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្ដល់ឯកសារ និងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៩ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ MOC-៩៣៣៩១៩៩ ពណ.ចបព ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២។

២- លក្ខន្តិកៈក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត បានតម្កល់ទុកលេខ ២០១៤/២០១២ ពណ.ចបព ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះបញ្ជិកាលេខ ២៩៨ រប/កធ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ របស់មន្ទីរការងារខេត្តកំពង់ឆ្នាំង។

៤- សារណាសង្ខេបនៃវិវាទការងាររបស់ក្រុមហ៊ុន ចុះថ្ងៃសៅរ៍ ៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- កំណត់ហេតុសួរព័ត៌មាននិយោជក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧- លិខិតស្នើសុំពន្យាពេលដោះស្រាយ ចុះថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

៨- សំណើសុំដោះស្រាយវិវាទការងាររួមក្រុមហ៊ុន បូវយើរ ឡើងវិញ ចុះថ្ងៃអង្គារ ៨រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៩- លិខិតលេខ ១៦៣៥/១៩ កប/អជក ចុះថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ជម្រាបមក លោកនាយកក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ស្តីពីបណ្តឹងឧបាស្រ័យ។

១០-លិខិតបញ្ឈប់លោកស្រី ហ៊ាន ស្រៀន ពីការងារពីក្រុមហ៊ុន ប៊ូវយើរ ហ្គាមេន ហ្វេកធើរី ចុះថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩។

១១- លិខិតជូនដំណឹងអំពីការទូទាត់ប្រាក់ឈ្នួលចុងក្រោយរបស់លោកស្រី ហ៊ាន ស្រៀន ចុះថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩។

១២- បណ្ណដាក់ប្រាក់ ធនាគារ អេស៊ីលីដា ភីអិលស៊ី។

១៣- លិខិតរបស់ថ្នាក់ដឹកនាំសហជីពអភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ គោរពជូនប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្ពុជា ជូនដំណឹងលាឈប់របស់សមាជិក និងថ្នាក់ដឹកនាំ។

១៤- លិខិតបង្កក់ការកាត់ភាគទានចូលកុងធនាគារអេស៊ីលីដាចូលក្នុងគណនយ្យរបស់សហជីពអភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

១៥- លិខិតសុំបដិសេធ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

១៦- លិខិតបញ្ជាក់ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

១៧- កំណត់ហេតុស្តីពីការដោះស្រាយករណីកូដកម្មនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃពុធ ៩កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩។

១៨- លិខិតផ្ទេរសិទ្ធិជូនលោក ផុត សុវត្ថា និងលោក ទិត ពេជ្របញ្ញា ចុះថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

១៩- តារាងស្នើសុំធ្វើការបន្ថែមម៉ោង។

២០- ឯកសារភាសាបរទេស។

THE ARBITRATION COUNCIL

២១- លិខិតប្ដឹងជំទាស់ ចុះថ្ងៃសៅរ៍ ៧កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៩។

២២- លិខិតជំទាស់ ចុះថ្ងៃព្រហស្បតិ៍ ២កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

២៣- លក្ខន្តិកៈនៃសហជីពអភិវឌ្ឍន៍កម្ពុជា ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះបញ្ជីលេខ ១០៨១៧០០១៧ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- វិញ្ញាបនបត្រចុះបញ្ជិកាអង្គការវិជ្ជាជីវៈសហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ០០៤៥/១៩ កប/កណ ចុះថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩។

២- លិខិតលេខ ០០៤៥/១៩ កប/កណ ចុះថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត ពិតជាបានចុះបញ្ជីពេញលក្ខណៈច្បាប់។

៣- វិញ្ញាបនបត្រចុះបញ្ជិកាអង្គការវិជ្ជាជីវៈសហជីពអភិវឌ្ឍន៍កម្ពុជា ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ០១៧/១៧ កប/កណ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧។

៤- លិខិតលេខ ៦៤៦/១៩ កប/កណ ចុះថ្ងៃចន្ទ ១កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល ជម្រាបមក លោកស្រីប្រធានសហជីពអភិវឌ្ឍន៍កម្ពុជា ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត ស្ដីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីអាណត្តិទី២។

៥- លិខិតព្យួរការងារលោកស្រី ហ៊ាន ស្រឿន ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩។

៦- វិញ្ញាបនបត្រចុះបញ្ជិកាអង្គការវិជ្ជាជីវៈសហជីពចលនាយុវជនដើម្បីសេរីភាព ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ០០៤៤/១៩ កប/កណ ចុះថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩។

៧- លិខិតលេខ លេខ ០០៤៤/១៩ កប/កណ ចុះថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពចលនាយុវជនដើម្បីសេរីភាព ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីធីត ពិតជាបានចុះបញ្ជីពេញលក្ខណៈច្បាប់។

៨- សារណាសង្ខេបនៃវិវាទ និងភស្តុតាង ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩។

៩- លិខិតសុំឱ្យបញ្ចូលប្រាក់ភាគទានក្នុងប្រព័ន្ធគណនីធនាគារ ចុះថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

១០- លិខិតលេខ ១៦៣៥/១៩ កប/អធក ចុះថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ជម្រាបមក លោកនាយកក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ស្តីពីបណ្តឹងឧបាស្រ័យ។

១១- លិខិតបង្កក់ការកាត់ភាគទានចូលកុងធនាគារអេស៊ីលីដាចូលក្នុងគណនយ្យរបស់សហជីព អភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

១២- លិខិតសុំបញ្ឈប់ការងារលោកស្រី ហ៊ាន ស្រឿន ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩។

១៣- វិក្កយបត្រ។

១៤- លក្ខន្តិកៈនៃសហជីពអភិវឌ្ឍន៍កម្ពុជា ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះបញ្ជីលេខ ១០៨១៧០០១៧ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧។

១៥- លិខិតលេខ ០០២៦/១៩ សអក ចុះថ្ងៃសុក្រ ១០រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ របស់លោកស្រី ហ៊ាន ស្រឿន គោរពជូន រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សំណើសុំអន្តរាគមន៍។

១៦- លិខិតលេខ ៧៣០/១៩ កប/កណ ចុះថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ ជម្រាបមក នាយកក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ករណីបញ្ឈប់លោកស្រី ហ៊ាន ស្រឿន។

១៧- លិខិតរបស់ថ្នាក់ដឹកនាំសហជីពអភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ គោរពជូនប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្ពុជា ជូនដំណឹងលាឈប់របស់សមាជិក និងថ្នាក់ដឹកនាំ។

១៨- រូបថត។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ៩៣៣/១៩ ក.ប/កណ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត លេខ ០២៦/១៩ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៦១១ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៤ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦១២ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៤រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងកាត់ដេរសម្លៀកបំពាក់។ ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតសរុបចំនួន ៤៥៥៦នាក់ (*យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា)*)។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ទេរប្រាក់ភាគទានដែលកាត់ចេញពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពអភិវឌ្ឍន៍កម្ពុជា ចូលទៅក្នុងគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា**

- ភាគីទាំងពីរទទួលស្គាល់ថា៖
  - សម្រាប់ខែសីហា និងខែកញ្ញា និយោជកបានផ្ទេរប្រាក់ភាគទានរបស់សហជីពអភិវឌ្ឍន៍កម្ពុជាចូលទៅក្នុងគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា។
  - សម្រាប់ខែតុលា និយោជកបានបើកប្រាក់ភាគទានរបស់សហជីពអភិវឌ្ឍន៍កម្ពុជា ឱ្យទៅកម្មករនិយោជិត សេង សុភ័ណ្ឌ ដែលជាប្រធានសហជីព។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា៖
  - និយោជកបានជ្រៀតជ្រែកនឹងការងារផ្ទៃក្នុងរបស់សហជីពអភិវឌ្ឍន៍កម្ពុជា និងបានឃុបឃិតជាមួយកម្មករនិយោជិត សេង សុភ័ណ្ឌ។
  - និយោជកបានទទួលយករាល់លិខិតដែលកម្មករនិយោជិត សេង សុភ័ណ្ឌ បានដាក់ជូន ប៉ុន្តែនិយោជកមិនដែលទទួលយកលិខិតដែលកម្មករនិយោជិត ហ៊ាន ស្រឿន ជាអនុប្រធានសហ-ជីព និង លី ផល្លា ជាលេខាធិការសហជីព ដាក់ជូនឡើយ។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ និយោជកបានទទួលលិខិតស្នើសុំបើកប្រាក់ភាគទានពីកម្មករនិយោជិត សេង សុភ័ណ្ឌ ដែលជាប្រធានសហជីពអភិវឌ្ឍន៍កម្ពុជា ទើបនិយោជកយល់ឃើញថា ក្នុងនាមជាប្រធានសហជីព សេង សុភ័ណ្ឌ មានសិទ្ធិទទួលយក និងចាត់ចែងប្រាក់ភាគទាន ហេតុនេះនិយោជកមិនបានជ្រៀតជ្រែកនឹងការងារផ្ទៃក្នុងរបស់សហជីពនោះទេ។

**ចំណុចវិវាទទី ៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុវត្តសេចក្តីសម្រេចរបស់អធិការការងារ លេខ ៧៣០/១៩ ក.ប/កណ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ ដែលតម្រូវឱ្យនិយោជកទទួលយកកម្មករនិយោជិត ហ៊ាន ស្រឿន ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃដែលត្រូវនិយោជកបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ហ៊ាន ស្រឿន ឱ្យចូលធ្វើការវិញ។
- ភាគីទាំងពីរទទួលស្គាល់ថា៖

THE ARBITRATION COUNCIL

- នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ អធិការការងារបានចេញសេចក្តីសម្រេចលេខ ៧៣០/១៩ ក.ប/កណ ដែលសម្រេចឱ្យនិយោជកទទួលយកកម្មករនិយោជិត ហ៊ាន ស្រឿន ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួលចាប់ពីថ្ងៃដែលនិយោជកបានបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។
- បន្ទាប់មក និយោជកបានប្តឹងឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើសេចក្តីសម្រេចរបស់អធិការការងារលេខ ៧៣០/១៩ ក.ប/កណ ហើយរដ្ឋមន្ត្រីបានកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ ដោយសម្រេចអនុញ្ញាតឱ្យនិយោជកបញ្ឈប់កម្មករនិយោជិត ហ៊ាន ស្រឿន។

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា៖
  - និយោជកអាចលើកសំអាងហេតុ និងអង្គហេតុបន្ថែមដែលមិនពិតប្រាកដនៅក្នុងបណ្តឹងឧបា-ស្រ័យ ទើបរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ។
  - បន្ទាប់ពីមានការវាយតប់គ្នារវាងកម្មករនិយោជិត ហ៊ាន ស្រឿន និងបុគ្គលិករដ្ឋបាល យ៉ង់ គង់ និយោជកបានបញ្ឈប់កម្មករនិយោជិត ហ៊ាន ស្រឿន ហើយពុំបានចាត់វិធានការភ្លាមៗលើលោក យ៉ង់ គង់ ដូចដែលបានអនុវត្តលើកម្មករនិយោជិត ហ៊ាន ស្រឿនឡើយ។ ផ្ទុយទៅវិញ និយោជកបានចាត់វិធានការលើលោក យ៉ង់ គង់ នៅខែកញ្ញា ឆ្នាំ២០១៩។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថាសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺយុត្តិធម៌ និងត្រឹមត្រូវស្របតាមច្បាប់។

**ចំណុចវិវាទទី ៥ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលកូដកម្ម**

- ភាគីទាំងពីរទទួលស្គាល់ថា៖
  - ភាគីកម្មករនិយោជិតបានធ្វើកូដកម្មរយៈពេល ៧ថ្ងៃ ចាប់ពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩។
  - និយោជកពុំបានជ្រើសរើសកម្មករនិយោជិតថ្មីដើម្បីជំនួសកម្មករនិយោជិតដែលជាកូដករនោះទេ។
  - នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ តាមរយៈកំណត់ហេតុស្តីពីការដោះស្រាយករណីកូដកម្មនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីតធីត ក្នុងករណីដែលកម្មករនិយោជិតចូលធ្វើការវិញនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ និយោជកឯកភាពផ្តល់ប្រាក់ឈ្នួលចំនួន ១ថ្ងៃកន្លះ ជូនកម្មករនិយោជិតធ្វើកូដកម្មនៅថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ តាមការស្នើសុំរបស់កម្មករនិយោជិត។
  - កម្មករនិយោជិតពុំបានចូលធ្វើការវិញនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ប៉ុន្តែ កម្មករនិយោជិតបានបន្តធ្វើកូដកម្មរហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការធ្វើកូដកម្មថា បុគ្គលិករដ្ឋបាល យ៉ង់ គង់ ប្រើប្រាស់សម្តីមិនសមរម្យដាក់កម្មករនិយោជិត និងបានកាត់បន្ថយអត្ថប្រយោជន៍ដែលកម្មករនិយោជិតធ្លាប់ទទួលបាន។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយសារនិយោជកអនុវត្តតាមមាត្រា ៣៣២ នៃច្បាប់ស្តីពីការងារ, បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីតធីត, និងកំណត់ហេតុស្តីពីការដោះស្រាយករណីកូដកម្មនៅក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកជើរី (ខេមបូឌា) ខមភេនី លីមីតធីត ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៩។

**ចំណុចវិវាទទី ៧ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករំលាយកិច្ចសន្យាសេវាសន្តិសុខជាមួយក្រុមហ៊ុនសន្តិសុខ វីអាយភី**

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា៖
    - ក្រុមហ៊ុនសន្តិសុខ វីអាយភី បានជ្រៀតជ្រែកនឹងការងាររបស់សហជីព ដោយយកឈ្មោះសហជីពអភិវឌ្ឍន៍កម្ពុជា ជាតំណាងដើម្បីស្នើសុំប្រាក់ពីនិយោជកសម្រាប់ធ្វើការងាររបស់សហជីព ប៉ុន្តែ ជាក់ស្តែង គាត់បានយកប្រាក់នោះទៅប្រើប្រាស់សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។
    - ក្រោមការបញ្ជារបស់និយោជក បុគ្គលិកសន្តិសុខនៃក្រុមហ៊ុន វីអាយភី បានប្រើអំពើហិង្សាលើកម្មករនិយោជិត ហ៊ាន ស្រឿន ដើម្បីរារាំងមិនឱ្យគាត់ចូលធ្វើការ នៅពេលអធិការការងារសម្រេចឱ្យចូលធ្វើការវិញ។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា
    - ក្រុមហ៊ុនសន្តិសុខ វីអាយភី បានចុះកិច្ចសន្យាជាមួយនិយោជក ដើម្បីផ្តល់សេវាសន្តិសុខ មិនមែនដើម្បីជ្រៀតជ្រែកនឹងការងាររបស់សហជីពនោះទេ។
    - ក្រុមហ៊ុនសន្តិសុខ វីអាយភី មិនបានយកឈ្មោះសហជីពអភិវឌ្ឍន៍កម្ពុជា ជាតំណាងដើម្បីស្នើសុំប្រាក់ពីនិយោជកសម្រាប់ធ្វើការងាររបស់សហជីពនោះទេ។
    - និយោជកមិនបានបញ្ជាបុគ្គលិកសន្តិសុខនៃក្រុមហ៊ុន វីអាយភី ឱ្យប្រើអំពើហិង្សាលើកម្មករនិយោជិតណាម្នាក់នោះទេ។

**ចំណុចវិវាទទី ១០ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ភាគកម្មនៃប្រាក់ចំណេញជូនកម្មករនិយោជិត**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ក្រុមហ៊ុន យ៉ុងវ៉ា និងធនាគារអេស៊ីលីដា បានផ្តល់ភាគកម្មនៃប្រាក់ចំណេញជូនកម្មករនិយោជិត ដូចនេះ និយោជកគួរតែពិចារណាក្នុងការផ្តល់ជូនកម្មករនិយោជិតនូវភាគកម្មនៃប្រាក់ចំណេញដូចក្រុមហ៊ុនដទៃបានអនុវត្ត។
- ភាគីនិយោជកពុំមានលទ្ធភាពផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតទេ ដោយមូលហេតុថា៖
    - និយោជកបានផ្តល់អត្ថប្រយោជន៍ជាច្រើនដែលលើសពីច្បាប់បានកំណត់។
    - កម្មករនិយោជិតខ្លះមិនបានបំពេញការងារដោយពេញលេញនោះទេ ពោលគឺកម្មករនិយោជិតខ្លះអង្គុយលេង ហើយខ្លះទៀតចេញពីធ្វើការមុនម៉ោងកំណត់ក្នុងក្រុមហ៊ុន។

ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ទេរប្រាក់ភាគទានដែលកាត់ចេញពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពអភិវឌ្ឍន៍កម្ពុជា ចូលទៅក្នុងគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្ទេរប្រាក់ភាគទានដែលកាត់ចេញពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពអភិវឌ្ឍន៍កម្ពុជា ចូលទៅក្នុងគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា ដែរ ឬទេ?

កថាខណ្ឌទី១ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីព ចែងថា៖ "*និយោជកត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពដើម្បីផ្ទេរទៅឱ្យសហជីពនោះជាស្វ័យប្រវត្តិ ក្រោយពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត។ បែបបទអនុវត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ*"។

កថាខណ្ឌទី១ ប្រការ ២ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ ចែងថា៖ "*បន្ទាប់ពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត និយោជកត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសាមី និងត្រូវតែផ្ទេរប្រាក់ភាគទាននោះចូលទៅក្នុងគណនីធនាគាររបស់សហជីពដែលកម្មករនិយោជិតនោះជាសមាជិក។ ត្រូវហាមឃាត់មិនឱ្យនិយោជកបង់ប្រាក់ភាគទាននេះជំនួសកម្មករនិយោជិត*"។

យោងតាមកថាខណ្ឌទី១ មាត្រា ២៦ នៃច្បាប់ស្តីពីការងារ និងកថាខណ្ឌទី១ ប្រការ ២ នៃប្រកាសលេខ ៣០០ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រោយពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត និយោជកត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសាមីដើម្បីបង់ប្រាក់ភាគទានជូនសហជីព ហើយត្រូវផ្ទេរប្រាក់ភាគទាននោះចូលទៅក្នុងគណនីធនាគាររបស់សហជីព ដែលកម្មករនិយោជិតសាមីជាសមាជិក។

តាមអង្គហេតុ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ និយោជកបានទទួលលិខិតស្នើសុំបើកប្រាក់ភាគទានសហជីព ពីកម្មករនិយោជិត សេង សុភ័ណ្ឌ ដែលជាប្រធានសហជីពអភិវឌ្ឍន៍កម្ពុជា ហើយនិយោជកបានផ្តល់ប្រាក់ភាគទានសម្រាប់ខែតុលា ឆ្នាំ២០១៩នេះ ឱ្យទៅកម្មករនិយោជិត សេង សុភ័ណ្ឌ ដោយផ្ទាល់ ហើយមិនបានផ្ទេរប្រាក់ភាគទាននេះ ទៅក្នុងគនណីធនគាររបស់សហជីពទេ។ យ៉ាងណាមិញ តាមស្មារតីនៃប្រការ ២ នៃប្រកាសលេខ ៣០០ និយោជកមានកាតព្វកិច្ចក្នុងការផ្ទេរប្រាក់ភាគទានចូលទៅក្នុងគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា ហេតុនេះ ការអនុវត្តរបស់និយោជក គឺមិនអនុលោមតាមប្រការ ២ នៃប្រកាសលេខ ៣០០ នោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកផ្ទេរប្រាក់ភាគទានដែលកាត់ចេញពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពអភិវឌ្ឍន៍កម្ពុជា ចូលទៅក្នុងគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា។

THE ARBITRATION COUNCIL

**ចំណុចវិវាទទី៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ហ៊ាន ស្រឿន ឱ្យចូលធ្វើការវិញ**

យោងតាមអង្គហេតុ កម្មករនិយោជិត ហ៊ាន ស្រឿន ត្រូវបានអធិការការងារសម្រេចឱ្យចូលធ្វើការវិញ ប៉ុន្តែ និយោជកបានប្តឹងឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើសេចក្តីសម្រេចរបស់អធិការការងារលេខ ៧៣០/១៩ ក.ប/កណ រដ្ឋមន្ត្រីបានកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ ដោយបានចេញសេចក្តីសម្រេចអនុញ្ញាតឱ្យនិយោជកបញ្ឈប់កម្មករនិយោជិត ហ៊ាន ស្រឿន។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការពិចារណាលើវិវាទនេះ ដែរ ឬទេ?

មាត្រា ៨៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចែងថា៖ "*ក្នុងករណីមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល សមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវប្រគល់ឱ្យតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់*"។

យោងតាមមាត្រា ៨៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅពេលដែលមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល មានតែតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ប៉ុណ្ណោះ ដែលមានយុត្តាធិការសម្រេចសេចក្តីលើរឿងក្តីរដ្ឋបាល។

យោងតាមអង្គហេតុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសម្រេចឱ្យនិយោជកបញ្ឈប់កម្មករនិយោជិត ហ៊ាន ស្រឿន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលពុំមានយុត្តាធិការក្នុងការសម្រេចសេចក្តីលើបណ្តឹងជំទាស់ទាក់ទងនឹងសេចក្តីសម្រេចឯកត្តកូតរបស់រដ្ឋមន្ត្រីនោះទេ។ បើសិនជាភាគីកម្មករនិយោជិតមិនយល់ស្របនឹងសេចក្តីសម្រេចឯកត្តកូតរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីកម្មករនិយោជិតអាចប្តឹងទៅតុលាការដែលមានយុត្តាធិការបាន ពីព្រោះយោងតាមមាត្រា ៨៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៅពេលដែលមិនទាន់សាលាជម្រះក្តីរដ្ឋបាល មានតែតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ប៉ុណ្ណោះ ដែលមានយុត្តាធិការសម្រេចសេចក្តីលើរឿងក្តីរដ្ឋបាល។

ហេតុនេះ យោងតាមមាត្រា ៨៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលយកកម្មករនិយោជិត ហ៊ាន ស្រឿន ឱ្យចូលធ្វើការវិញ។

**ចំណុចវិវាទទី ៥ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលកូដកម្ម**

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលកូដកម្ម ដែរ ឬទេ?

កថាខណ្ឌទី១ មាត្រា ៣៣២ នៃច្បាប់ស្តីពីការងារ ចែងថា៖ "*កិច្ចសន្យាការងារត្រូវព្យួរនៅពេលធ្វើកូដកម្ម។ ក្នុងអំឡុងពេលនៃកូដកម្ម តាវកាលិកការងារមិនត្រូវបានផ្តល់ឱ្យទេ ហើយប្រាក់បៀវត្សមិនត្រូវបានបើកឱ្យដែរ*"។

កថាខណ្ឌទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារ ចែងថា៖ "*ការព្យួរកិច្ចសន្យាការងារ នាំឱ្យប៉ះពាល់ចំពោះតែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត*"។

នៅក្នុងសំណុំរឿងមុន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកត់សំគាល់ថា យោងតាមមាត្រា ៣៣២ នៃច្បាប់ស្តីពីការងារ អត្ថន័យនៃមាត្រានេះ គឺ កម្មករនិយោជិតដែលធ្វើកូដកម្មមិនអាចទទួលបាននូវប្រាក់ឈ្នួលទេ នៅអំឡុងពេលធ្វើកូដកម្ម ទោះបីជាកូដកម្មនោះ ធ្វើឡើងដោយស្របតាមច្បាប់ស្តីពីការងារ ឬកូដកម្មមិនស្របច្បាប់ស្តីពីការងារក៏ដោយ ក៏កម្មករនិយោជិតទាំងអស់នោះ មិនអាចទទួលបានប្រាក់ឈ្នួលដែរ ក្នុងពេលធ្វើកូដកម្ម (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៩/០៥-អូ សេ អង់ ហ្គាមិន ហេតុផលនៃចំណុចវិវាទទី៣*)។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

មាត្រា ៣៣៤ នៃច្បាប់ស្តីពីការងារ ចែងថា៖ "*ក្នុងអំឡុងពេលធ្វើកូដកម្ម ត្រូវហាមឃាត់មិនឱ្យនិយោជកជ្រើសរើសកម្មករនិយោជិតផ្សេងមកជំនួសកូដករទាំងអស់... រាល់ការរំលោភលើវិធាននេះ តម្រូវឱ្យនិយោជកមានកាតព្វកិច្ច បើកប្រាក់បៀវត្សឱ្យកម្មករនិយោជិតដែលជាកូដករទាំងអស់ នៅក្នុងរយៈពេលធ្វើកូដកម្ម*"។

តាមរយៈមាត្រានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្នុងអំឡុងពេលធ្វើកូដកម្ម និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតដែលជាកូដករនោះទេ ប៉ុន្តែ ក្នុងករណីដែលនិយោជកបានជ្រើសរើសកម្មករនិយោជិតថ្មីដើម្បីជំនួសកូដករនោះ និយោជកមានកាតព្វកិច្ចផ្តល់ប្រាក់បៀវត្សដល់កម្មករនិយោជិតដែលជាកូដករទាំងនោះ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧៨/១២-ដេខ្សូ (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១ ទី២ និងទី៣ និងលេខ ០៩/១៤-ស៊ីណូ ហ្កាមេន*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

ទន្ទឹមនឹងនេះ មាត្រា ៣២៤ នៃច្បាប់ស្តីការងារ ចែងថា៖ "*ការធ្វើកូដកម្ម ត្រូវជូនដំណឹងមុនក្នុងរយៈពេលយ៉ាងតិច ប្រាំពីរថ្ងៃ គិតតែថ្ងៃធ្វើការហើយត្រូវតម្កល់ទុកនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន*"។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតមិនបានបង្ហាញថា កម្មករនិយោជិតបានជូនដំណឹងនៅមុនពេលធ្វើកូដកម្មនៅថ្ងៃទី៨ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩នោះទេ។ ភាគីនិយោជកក៏មិនបានជ្រើសរើសកម្មករនិយោជិតថ្មីដើម្បីជំនួសកូដករនោះដែរ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមិនបានអនុវត្តការធ្វើកូដកម្មឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់តម្រូវនោះទេ ហើយនិយោជកក៏មិនមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតកូដករនោះដែរ។ ដូចនេះ កម្មករនិយោជិតមិនមានសិទ្ធិទទួលបានប្រាក់ឈ្នួល និងតាវកាលិកផ្សេងៗ សម្រាប់រយៈពេលដែលពួកគាត់ធ្វើកូដកម្មទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជករក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលកូដកម្ម។

THE ARBITRATION COUNCIL

**ចំណុចវិវាទទី ៧ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករំលាយកិច្ចសន្យាសេវាសន្តិសុខជាមួយក្រុមហ៊ុនសន្តិសុខ វីអាយភី**

នៅក្នុងសវនការ ភាគីកម្មករនិយោជិតបានលើកឡើងថា ក្រុមហ៊ុនសន្តិសុខ វីអាយភី បានជ្រៀតជ្រែកនឹងការងាររបស់សហជីព និងបានប្រើអំពើហិង្សាលើកម្មករនិយោជិត ហ៊ាន ស្រឿន។ ដូចនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករំលាយកិច្ចសន្យាសេវាសន្តិសុខជាមួយក្រុមហ៊ុនសន្តិសុខ វីអាយភី។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការ សម្រេចលើការទាមទារឱ្យនិយោជករំលាយកិច្ចសន្យាសេវាសន្តិសុខជាមួយក្រុមហ៊ុនសន្តិសុខ វីអាយភី ដែរឬទេ?

ប្រការ ៣២ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ កំណត់ថា៖ *"ក្រុមអាជ្ញា-កណ្តាលត្រូវសំរេចសេចក្តីលើវិវាទការងាររួមដែលដាក់មកខ្លួន ដោយយោងទៅតាមមាត្រា ៣០៩ កថាខ័ណ្ឌ គ នៃច្បាប់ស្តីពីការងារ"*។

មាត្រា ៣០២ នៃច្បាប់ការងារ ចែងថា៖ *"វិវាទការងាររួម គឺជាវិវាទដែលកើតឡើង... អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស ...រវាងនិយោជក និងកម្មករនិយោជិត..."*។

ផ្អែកលើមាត្រា ៣០២ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មវត្ថុចម្បងនៃវិវាទការងាររួមដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការសម្រេចសេចក្តី គឺជាវិវាទការងាររួម ដែលទាក់ទងនឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស ជាដើម។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតនៅក្នុងចំណុចវិវាទទី៧នេះ មិនមែនជាកម្មវត្ថុនៃវិវាទការងាររួម ដែលមានចែងក្នុងមាត្រា ៣០២ ខាងលើឡើយ ដោយឡែកកម្មវត្ថុនៃការទាមទារនេះ គឺទាក់ទងនឹងកិច្ចសន្យាសេវាសន្តិសុខរវាងនិយោជក និងក្រុមហ៊ុនសន្តិសុខ វីអាយភី។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការសម្រេចសេចក្តីលើចំណុចវិវាទនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជករំលាយកិច្ចសន្យាសេវាសន្តិសុខជាមួយក្រុមហ៊ុនសន្តិសុខ វីអាយភី។

**ចំណុចវិវាទទី ១០ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ភាគកម្មនៃប្រាក់ចំណេញជូនកម្មករនិយោជិត**

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ភាគកម្មនៃប្រាក់ចំណេញជូកម្មករនិយោជិត ដែរ ឬទេ?

មាត្រា ២ នៃច្បាប់ស្តីពីការងារ ចែងថា៖ *"...សហគ្រាសនិមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននិមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្ររោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រងនិងដឹកនាំរបស់និយោជក"*។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ នៃច្បាប់ស្តីពីការងារខាងលើមានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និង សមហេតុផល ( *សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីកស៊ូ ហេតុផលនៃចំណុចវិវាទទី៥, លេខ ១០៨/០៦-ទ្រីនុងហ្គាល ក្មុំម៉ាក់, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣*

*លេខ ១១៩/០៩-អេស អិល ហេតុផលនៃចំណុចវិវាទទី៤ និងទី៥, និងលេខ ០២៩/១៥-ប្រ៊ីជីស អ៊ីមើរីខិន ចឺប៊ែកខូ ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៣ ទី៤ និងទី៥*)។

ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា៖ *"និយោជកតាមរយៈការសំរេចឯកតោភាគី អាចរៀបចំផែនការផ្តល់ប្រាក់រង្វាន់ផ្សេងៗ ក្រៅពីប្រាក់រង្វាន់ដែលកំណត់ក្នុងច្បាប់ការងារ ដើម្បីជំរុញ ឬលើកទឹកចិត្តកម្មករនិយោជិតខិតខំធ្វើឱ្យមានផលិតកម្មច្រើន ហើយប្រើពេលវេលាតិច"* (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៤/០៥-វ៉េវ វែល ហេតុផលនៃចំណុចវិវាទទី២, លេខ០៣/១៣-តៃ វ៉ាង ព្រីនធីង ហេតុផលនៃចំណុចវិវាទទី១, និងលេខ ០២៩/១៥-ប្រ៊ីជីស អ៊ីមើរីខិន ចឺប៊ែកខូ ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៣ ទី៤ និងទី៥*)។

នៅក្នុងសំណុំរឿងលេខ ០២៩/១៥-ប្រ៊ីជីស អ៊ីមើរីខិន ចឺប៊ែកខូ ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៣ ទី៤ និងទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា៖ *"ការផ្តល់ភាគកម្មនៃប្រាក់ចំណេញ គឺនិយោជកមានសិទ្ធិចាត់ចែង ដោយអាចដាក់លក្ខខណ្ឌផ្សេងៗលើភាគកម្មនៃប្រាក់ចំណេញបាន ដរាបណាការចាត់ចែងនោះ មានលក្ខណៈសមហេតុផល និងស្របច្បាប់"* (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០១៣/១៧-សាយ៉ាម អ៊ិនធើណេសិនណល ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានច្បាប់ ឬបទបញ្ញត្តិផ្សេងៗ ឬកិច្ចព្រមព្រៀងណាមួយដែលតម្រូវឱ្យនិយោជកផ្តល់ភាគកម្មនៃប្រាក់ចំណេញជូនកម្មករនិយោជិតនោះទេ។ ហេតុនេះ ក្នុងករណីនេះ ការផ្តល់ភាគកម្មនៃប្រាក់ចំណេញជូនកម្មករនិយោជិត គឺស្ថិតនៅក្រោមការចាត់ចែងរបស់និយោជក។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ភាគកម្មនៃប្រាក់ចំណេញជូនកម្មករនិយោជិត។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ៣ ៖**

- បង្គាប់ឱ្យនិយោជកផ្ទេរប្រាក់ភាគទានដែលកាត់ចេញពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពអភិវឌ្ឍន៍កម្ពុជា ចូលទៅក្នុងគណនីធនាគាររបស់សហជីពអភិវឌ្ឍន៍កម្ពុជា។

**ចំណុចវិវាទទី ៤ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលយកកម្មករនិយោជិត ហ៊ាន ស្រឿន ឱ្យចូលធ្វើការវិញ។

**ចំណុចវិវាទទី ៥ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗក្នុងអំឡុងពេលកូដកម្ម។

**ចំណុចវិវាទទី ៧ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជករំលាយកិច្ចសន្យាសេវាសន្តិសុខជាមួយក្រុមហ៊ុនសន្តិសុខ វីអាយភី។

**ចំណុចវិវាទទី ១០ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ភាគកម្មនៃប្រាក់ចំណេញជូនកម្មករនិយោជិត។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **សេខ ឌួចហ៊ុន**

ហត្ថលេខា ៖ ----------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖----------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ប៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ----------------------------

THE ARBITRATION COUNCIL